# ដំណឹងចូលរួមដេញថ្លៃ

## គម្រោងសាលាបៃតង ជំហាន ៤.០ ដំណាក់កាលទី ២

អង្គការ បូដា កម្ពុជា (BORDA Cambodia) សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុនសាងសង់ទាំងអស់ដែលមានបំណងចង់ចូលរួមដេញថ្លៃឱ្យបានជ្រាបថា៖ អង្គការ បូដា កម្ពុជា (BORDA Cambodia) មានគម្រោងផ្ដល់នូវហេដ្ឋារចនាសម្ព័ន្ធអនាម័យតាមសាលាបឋមសិក្សា មានដូចជា៖ សាងសង់បង្គន់ថ្មី ឬ ជួសជុលបង្គន់អនាម័យមានស្រាប់ សាងសង់បង្គន់នោមកុមារា សាងសង់កន្លែងលាងដៃនៅមុខបង្គន់ កន្លែងលាងដៃជាក្រុម តបណ្ដាញទឹកស្អាត និង សាងសង់អាងប្រព្រឹត្តិកម្មទឹកកខ្វក់ខ្នាតតូច។ នៅដំណាក់កាលសាងសង់ទី២នេះ មានសាលាបឋមសិក្សាសរុបចំនួន ១២ សាលា ស្ថិតនៅក្រុងសិរីសោភ័ណ្ឌ ស្រុកអូរជ្រៅ ក្រុងប៉ោយប៉ែត និង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដែលទទួលបានការគាំទ្រថវិកាពីអង្គការ ការីតាស ស្វីស។

### លក្ខខណ្ឌចាំបាច់ក្នុងការចូលរួម៖

១. ក្រុមហ៊ុនត្រូវមានវិញ្ញាបនប័ត្រ ចុះបញ្ជីពីក្រសួងឬមន្ទីរពាណិជ្ជកម្ម (មានបញ្ជាក់ច្បាប់ដើម)។
២. ក្រុមហ៊ុនត្រូវមានប័ណ្ណប៉ាតង់ប្រកបអាជីវកម្ម ឆ្នាំ ២០២៣ ឬ ២០២៤ (មានបញ្ជាក់ច្បាប់ដើម)។
៣. ក្រុមហ៊ុនសាងសង់ដែលមានអាស័យដ្ឋានស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យ ត្រូវបានផ្ដល់អាទិភាពខ្ពស់ក្នុងការចូលរួម។
៤. ក្រុមហ៊ុនត្រូវមានបទពិសោធន៍លើការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធទឹកនិងអនាម័យតាមសាលារៀន ឬ គម្រោងសាងសង់ប្រហាក់ប្រហែលកន្លងមក។

### ការរៀបចំឯកសារចូលរួម៖

១. សូមក្រុមហ៊ុនដែលមានបទពិសោធន៍ទាក់ទងនឹងការងារខាងលើ និងបើមានចំណាប់អារម្មណ៍ចំពោះគម្រោងនេះ សូមផ្ញើរឯកសារជីវប្រវត្តិក្រុមហ៊ុន (Company profile) មកការិយាល័យអង្គការ បូដា កម្ពុជា (BORDA Cambodia) ត្រឹមថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០២៤ វេលាម៉ោង ០៥:០០ រសៀល ជាកំហិត។
២. ក្រុមហ៊ុនដែលបានជាប់នៅក្នុងបញ្ជីសម្រាំង នឹង ត្រូវបានអញ្ជើញចូលរួមដេញថ្លៃជាមួយគម្រោងសាលាបៃតង។

### ការចូលរួមដេញថ្លៃ៖

១. ឯកសារដេញថ្លៃត្រូវបានផ្ដល់ជូនអ្នកម៉ៅការដោយឥតគិតថ្លៃ

២.  អ្នកមៅការត្រូវផ្ញើឯកសារដេញថ្លៃដែលបានបំពេញរួចដាក់ក្នុងស្រោមបិទជិតមកការិយាល័យ អង្គការ បូដា កម្ពុជា )BORDA Cambodia( (រួមទាំងប្រាក់កក់ចំនួន ៥០០ ដុល្លារ)។
៣.  លទ្ធផលនៃការដេញថ្លៃនឹងត្រូវបានបិទផ្សាយជាសាធារណៈនៅមុខការិយាល័យរបស់អង្គការ បូដា កម្ពុជា (BORDA Cambodia) ដែលមានទីតាំងខាងក្រោម។

## សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនង៖

អាសយដ្ឋាន៖ ផ្ទះលេខ០១ ផ្លូវ៣៦៦ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
ទូរស័ព្ទទំនាក់ទំនង៖ ០៩៣ ៩១០ ៥០៥ / ០២៣ ២១៨ ០៨៤ ឬ អ៊ីម៉ែល: setha@borda-sea.org /
ព័ត៌មានលម្អិតសម្រាប់តម្រូវការឯកសារផ្សេងៗរបស់ក្រុមហ៊ុន  សូមទាញយកឯកសារក្នុងតំណភ្ជាប់ខាងក្រោម: https://drive.google.com/file/d/11O6eOCd37sblwwh6xwNXVRrLtNkNxMoP/view?usp=sharing